# មជ្ឈមណ្ឌលឯកសារកម្ពុជា

**បាឋកថាស្តីអំពី**
**«ការកាត់ទោសនិងការប៉ះប៉ូវជាសំណងក្នុងករណីបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌នៅក្នុងប្រទេសក្រោយជម្លោះ »**
ដោយ បណ្ឌិត លុក ម៉ូហ្សេត

**ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ៣:០០ រសៀល**
ទីតាំង: វិចិត្រសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
អគារ H វិទ្យាស្ថានជាតិអប់រំ
ភាសា: អង់គ្លេស (បកប្រែជាភាសាខ្មែរ)

វិចិត្រសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សូមជូនដំណឹងថា វិចិត្រសាលនឹងរៀបចំបាឋកថាទីម្ភៃ ស្តីអំពី **«ការកាត់ទោស និងការប៉ះប៉ូវជាសំណងក្នុងករណីបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌នៅក្នុងប្រទេសក្រោយជម្លោះ»** ដោយ បណ្ឌិត លុក ម៉ូហ្សេត។ សិស្ស និស្សិត គរុសិស្ស និងសាធារណជន អាចចូលរួមកម្មវិធីនេះដោយសេរី។

ទិដ្ឋភាពនៃទីតាំងបុរាណស័ក្តិសិទ្ធដែលត្រូវបានដាក់គ្រាប់ឱ្យផ្ទុះនិងជាប់បំផ្លាញដោយក្រុមសកម្មប្រយុទ្ធមកពីប្រទេសអាហ្គានីស្ថាន បូស្នៀ ម៉ាលី និងស៊ីរី បានធ្វើឱ្យពិភពលោកមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ អំពើទាំងអស់នេះធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រពៃណីក្នុងតំបន់។ ទន្ទឹមនឹងពេលដែលច្បាប់អន្តរជាតិធ្វើការហាមប្រាមការបំផ្លិចបំផ្លាញបែបនេះនិងចាត់ទុកអំពើនេះថាជាឧក្រិដ្ឋកម្មអន្តរជាតិ ហើយរដ្ឋទាំងឡាយមានកាតព្វកិច្ចក្នុងការថែរក្សានិងការពារសម្បត្តិវប្បធម៌ ការផ្តោតទៅលើការកាត់ទោសនិងសំណង នៅមិនទាន់ទទួលបានការយកចិត្តដាក់ខ្លាំងនៅឡើយ។ ការកាត់ក្តី អាម៉ាដ អាល់ ហ្វាគី អាល់ ម៉ាឌី នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិស្តីពីបទបំផ្លិចបំផ្លាញវិមានសាកសពនៅទីក្រុងទីមបុកទូ គឺជាសំណុំរឿងទីមួយដែលបុគ្គលប្រព្រឹត្តទទួលការកាត់ទោស ហើយមានកាតព្វកិច្ចសងជាសំណងទៅកាន់សហគមន៍ដែលរងឥទ្ធិពលពីការបំផ្លិចបំផ្លាញវប្បធម៌។ ទោះបីជា ជនដៃដល់មួយចំនួនធំត្រូវបានកាត់ទោសនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិយូហ្គោស្លាវីក៏ដោយ ក៏សំណងមិនដែលបានបញ្ចូលនៅក្នុងការសម្រេចដែរ។ លើកលែងតែក្នុងករណីពិសេសមួយចំនួនដែលទីតាំងបុរាណមិនអាចមានអ្វីមកជំនួសបាន សំណងត្រូវបានសម្រេចឱ្យអនុវត្តទៅលើករណីបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌។ បទបង្ហាញនេះនឹងពិភាក្សាទៅលើបទពិសោធន៍ទាំងអស់នេះ ការកាត់ទោសនិងសំណងដែលពាក់ព័ន្ធទៅនឹងការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌នៅប្រទេសស៊ីរី និងបញ្ហាប្រឈមផ្សេងៗ។

បណ្ឌិត លុក ម៉ូហ្សេត គឺជាប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្ស នៅសាលាច្បាប់នៃសកលវិទ្យាល័យឃ្វីន ចក្រភពអង់គ្លេស។ ការស្រាវជ្រាវរបស់គាត់ផ្តោតទៅលើសិទ្ធិជនរងគ្រោះ សំណង និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ បណ្ឌិត លុក ធ្វើការយ៉ាងជិតស្និទ្ធិជាមួយជនរងគ្រោះនៅប្រទេសអៀរឡង់ខាងជើង និងអ៊ុយហ្គានដា ទាក់ទងនឹងសំណង រួមទាំងការដាក់ពាក្យសុំសំណងទៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ថ្មីៗនេះ ជាមួយនឹងបណ្ឌិត រ៉េចល គីលានលោកបានបង្កើតគ្លីនិកសិទ្ធិជនរងគ្រោះ ជាមួយ REDRESS និងក្រុមការងារសិទ្ធិជនរងគ្រោះដើម្បីជម្រុញការយល់ដឹងអំពីសិទ្ធិជនរងគ្រោះនៅតុលាការអន្តរជាតិ។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**
ការចងចាំ និងយុត្តិធម៌
«...សង្គមមួយមិនអាចស្គាល់ខ្លួនឯងបាន ប្រសិនបើសង្គមនោះមិនមានការចងចាំដ៏ត្រឹមត្រូវអំពីប្រវត្តិសាស្ត្ររបស់ខ្លួន។»
ម៉ែន ពិចិត្រ
វិចិត្រសាលសិល្បៈសហសម័យ
មជ្ឈមណ្ឌលឯកសារកម្ពុជា
ទូរសព្ទ +៨៥៥ ២៣ ២១៤ ០០៩
អ៊ីម៉ែល truthmpechet@dccam.org
គេហទំព័រ www.dccam.org